**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ជូនលី អ៊ិនធើណេសិនណល ឯ ក**
អាសយដ្ឋាន៖ ភូមិ ស្វាយ   ឃុំ សំរោង
ស្រុក សំរោង ខេត្ត តាកែវ

# កិច្ចព្រមព្រៀង
## ស្តីអំពីការសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត
## ចំនួន ១៣០នាក់ រយៈពេល ១១ថ្ងៃ

នាថ្ងៃពុធ ១២រោច ខែផល្គុណ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០២១ លោកគា គុយហេង ដែលជាប្រធានរដ្ឋបាល របស់រោងចក្រស្បែកជើង ជូនលី អ៊ិនធើណេសិនណល ឯ ក បានបើកកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និង សហជីពប្រចាំរោងចក្រ **ស្តីអំពីការសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត** ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំខ្វះវត្ថុធាតុដើម ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៣០នាក់ (ស្រី ១០២នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៣៩៣នាក់ (ស្រី ៣៤៤នាក់) រយៈពេល ១១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១។ ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតដោយយោងទៅតាមសេចក្តីណែនាំលេខ ០៤៥/២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

### ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម

**ប្រការ១៖** ភាគីទាំងពីរយល់ព្រមអោយមានការសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៣០នាក់ (ស្រី ១០២នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៣៩៣នាក់ (ស្រី ៣៤៤នាក់) រយៈពេល ១១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១។

**ប្រការ២៖** ភាគីទាំងពីរយល់ព្រមអោយមានផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតដោយយោងទៅតាមសេចក្តីណែនាំលេខ ០៤៥/២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

(កិច្ចព្រមព្រៀងនេះធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការការបង្ខិតបង្ខំរវាងរោងចក្រ តំណាងប្រតិភូបុគ្គលិក និង សហជីព)

តាកែវ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២១
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

**តំណាងសហជីព**

លោក ឡាយ សុភក្តី

លោក អ៊ូច ជាតិ

លោកស្រី ទិត្យ សុជាតិ

**តំណាងប្រតិភូបុគ្គលិក**

លោកស្រី ហេង គឹមលាង

លោកស្រី ស៊ឹម សេងហុង

លោកស្រី ជុំ សុភាព